ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

# អនុសាសន៍ ៦ ចំណុច
# ដែលក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
# បានលើកជូនរាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់ បង្ការ បង្ក្រាប
# និងផ្តន្ទាទោសជនល្មើស ដើម្បីលើកឡើងនូវវិធានការជួយជនរងគ្រោះក្នុងឆ្នាំ ២០០៥

៤៤ ✱ ៦៦

ក្នុងឆ្នាំ ២០០៣ និងឆ្នាំ ២០០៤ ក.ជ.ក.ស. បានចុះតាមដានវាយតំលៃការអនុវត្តច្បាប់ ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស និងតាមដានការទប់ស្កាត់អំពើហិង្សាគ្រប់ប្រភេទលើស្ត្រីនៅតាមខេត្ត-ក្រុងចំនួន ១៦ ។ តាមរយៈការចុះធ្វើការផ្ទាល់ជាមួយអភិបាលខេត្ត ក្រុង ស្នងការនគរបាល តុលាការ មន្ទីរ-កិច្ចការនារី អង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ (ADHOC - LICADHO - CWCC...) ក.ជ.ក.ស. បានកត់សម្គាល់ឃើញមានបញ្ហាមួយចំនួន ដែលគួររៀនសូត្រ ដកបទពិសោធន៍ និងត្រូវលើកជាអនុសាសន៍ជូនរាជរដ្ឋាភិបាល សំដៅទប់ស្កាត់ បង្ការ បង្ក្រាប និងផ្តន្ទាទោសជនល្មើស ដើម្បីលើកឡើងនូវវិធានការជួយជនរងគ្រោះ ។ អនុសាសន៍ទាំងនោះរួមមាន :

១-កិច្ចសហការល្អរវាងស្នងការនគរបាល និងតុលាការខេត្ត ក្រុង គឺជាកត្តាកំណត់ជោគជ័យ ឬបរាជ័យក្នុងការផ្តន្ទាទោសជនល្មើស ។ ខេត្ត ក្រុងណា ដែលស្ថាប័នអនុវត្តច្បាប់ទាំងពីរសហការគ្នាល្អ ការអនុវត្តច្បាប់គឺមានប្រសិទ្ធភាព ។ ដោយឡែកខេត្ត ក្រុងណា ដែលស្ថាប័នអនុវត្តច្បាប់ទាំងពីរ មើលបំណាំគ្នា ធ្វើយដាក់គ្នា គឺការអនុវត្តច្បាប់ គ្មានប្រសិទ្ធភាព ធ្វើឱ្យជនល្មើសរួចខ្លួនពីទោសទណ្ឌ ។

<u>អនុសាសន៍</u>: សូមក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ជួយណែនាំបន្ថែមដល់មន្ទីរទាំងពីរខាងលើឱ្យសហការគ្នាល្អ ។

២-ខ្លឹមសារនៃច្បាប់ ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ត្រង់ជំពូក ទី ២ មាត្រា ៣ និងមាត្រា ៤ ហាក់ដូចជាពុំទាន់ច្បាស់លាស់នៅឡើយ ដែលជាហេតុធ្វើឱ្យមានការបកស្រាយខុសៗគ្នា ពីសំណាក់ស្ថាប័នមានសមត្ថកិច្ច នាំឱ្យជនប្រព្រឹត្តបទល្មើសរួចខ្លួន ។

<u>អនុសាសន៍</u>: សូមរាជរដ្ឋាភិបាលបំរុញការពិនិត្យសេចក្តីព្រាងច្បាប់ថ្មី ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឱ្យបានឆាប់ និងបញ្ជូនទៅរដ្ឋសភាពិនិត្យ និងអនុម័ត ។

៣-ទោះបីជាមានការណែនាំរបស់ ក្រសួងមហាផ្ទៃ ហើយក្ដី ក៏ជាក់ស្ដែងភាគច្រើននៃករណីរំលោភសេព-សន្ថវៈនៅតាមមូលដ្ឋាន ច្រើនដោះស្រាយជាកិច្ចសម្រុះសម្រួលដោយសំណងរដ្ឋប្បវេណីរវាងជនល្មើស និងជនរងគ្រោះចំពោះមុខរដ្ឋអំណាចមូលដ្ឋាន ដោយពុំបានផ្ដន្ទាទោសជនល្មើសតាមច្បាប់ព្រហ្មទណ្ឌ ជាហេតុធ្វើឱ្យអំពើនេះកាន់តែកើនឡើងពុំរាងចាល ។

<u>អនុសាសន៍</u>: សំណូមពរអាជ្ញាធរខេត្ត ក្រុង បិទកន្លែងបញ្ចាំងវីដេអូអាសអាភាស ដែលជាកត្តាអាក្រក់បំផុតនាំឱ្យកើនឡើងនូវអំពើចាប់រំលោភសេពសន្ថវៈ ជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ ។ សូមជួយធ្វើការអប់រំដល់សាធារណៈជនឱ្យយល់ដឹងអំពីសិទ្ធិ និងអំពីនីតិវិធីតុលាការ និងជួយហ្វឹកហ្វឺនដល់មន្ត្រីប៉ូលីសយុត្តិធម៌ រដ្ឋអំណាចមូលដ្ឋានឱ្យយល់ដឹងពីច្បាប់ និងភារកិច្ចរបស់ខ្លួន ។

៤-ការធ្វើកោសល្យវិច្ច័យជួបការលំបាកយ៉ាងខ្លាំងនៅតាមមូលដ្ឋាន ឃុំ-ភូមិ ដោយមណ្ឌលសុខភាពបង្អែក ពុំអាចចេញលិខិតបញ្ជាក់លទ្ធផលទាន់ពេលវេលា និងទាមទារការចំណាយថវិកាច្រើន ហើយជូនកាលហួសរយៈពេល ២៤ម៉ោង បាត់ភស្តុតាង ធ្វើឱ្យជនល្មើសរួចខ្លួន ។

<u>អនុសាសន៍</u>: ក្រសួងសុខាភិបាល គួរពិនិត្យផ្ដល់សេវាឱ្យទាន់ពេលវេលា ដោយយកតម្លៃទាប ឬមិនបាច់បង់ថ្លៃ និងត្រូវមានមន្ទីរពិសោធន៍ដែលមានវិជ្ជាជីវៈខ្ពស់ ។

៥-ការចាប់រំលោភសេពសន្ថវៈលើកូនស្រីបង្កើត ក្មួយស្រីបង្កើត កូនប្រពន្ធដើម និងការលក់ដូរកូនស្រីឱ្យធ្វើជាពេស្យាចារ ដោយមូលហេតុក្រីក្រ ធ្វើឱ្យស្រុតចុះយ៉ាងខ្លាំងនូវសីលធម៌សង្គម និងតម្លៃគ្រួសារខ្មែរនាពេលបច្ចុប្បន្ន ។

អនុសាសន៍: សូមក្រសួងពាក់ព័ន្ធទាំងអស់ ចូលរួមផ្សព្វផ្សាយតាមគ្រប់មធ្យោបាយ ដើម្បីស្ដារឡើងវិញនូវសីលធម៌ សង្គម និងតម្លៃគ្រួសារខ្មែរ និងដាក់ទណ្ឌកម្មឱ្យធ្ងន់ធ្ងរបំផុតដល់ជនល្មើសខាងលើ ។

៦-បញ្ហាបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ជាការចូលរួមចំណែកអនុវត្តគោលនយោបាយចតុ-កោណរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្រ តែក៏ជាបញ្ហាប្រឈមមុខនឹងការជួញដូរផ្លូវភេទដោយជនឱកាសនិយមផងដែរ ។

<u>អនុសាសន៍</u>: សូមក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងក្រុមហ៊ុនពាក់ព័ន្ធ ត្រូវមានវិធានការថ្មីបន្ថែមទៀត សម្រាប់គ្រប់គ្រងពលករដែលទៅធ្វើការនៅក្រៅប្រទេសឱ្យបានល្អ ហើយស្ថានទូតខ្មែរនៅបរទេស គួរមានវិធានការជួយធ្វើអន្តរាគមន៍ឱ្យមានប្រសិទ្ធភាព។

អនុសាសន៍ មួយចំនួនខាងលើនេះ ជាកត្តាមួយសំខាន់ណាស់ចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរិះរកវិធានការទប់ស្កាត់ភាពអសកម្ម នៃការអនុវត្តច្បាប់ ស្ដីពីការជួញដូរស្ត្រី និងកុមារ ។

❁❁❁❁